**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

**សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល**

**ស្តីពី**

**ការរកឃើញ ២៩ ករណីថ្មីទៀត ជាបុរសទេសចរជនជាតិបារាំង និងជនជាតិខ្មែរ ០២ នាក់**
**វិជ្ជមានវីរុសកូវីដ១៩ នៅខេត្តព្រះសីហនុ**

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា លទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា នាថ្ងៃទី២២ ខែមីនា ឆ្នាំ២០២០ វេលាយប់ម៉ោង២២:០០នាទី បានបង្ហាញថា សំណាកវត្ថុវិភាគរបស់បុរសនិងស្ត្រីជនជាតិបារាំងចំនួន ២៩នាក់ និងបុរសជនជាតិខ្មែរចំនួន ០២ នាក់ វិជ្ជមានវីរុសកូវីដ១៩ ជាករណីថ្មីបន្ថែមទៀតរកឃើញនៅខេត្តព្រះសីហនុ មានដូចខាងក្រោមនេះ៖

**១. នៅខេត្តព្រះសីហនុ៖ ២៩ ករណី ជាជនជាតិបារាំង ជាអ្នកទេសចរតាមក្រុមហ៊ុនទេសចរមួយ**

ពួកគាត់ជាស្ត្រី (អាយុ ៤៨ឆ្នាំ ៥៩ឆ្នាំ ៦៦ឆ្នាំ ៦១ឆ្នាំ ៦៣ឆ្នាំ ៥២ឆ្នាំ ៦២ឆ្នាំ ៦៦ឆ្នាំ ៥៩ឆ្នាំ ៦៣ឆ្នាំ ៧៦ឆ្នាំ ៦០ឆ្នាំ ៦៣ឆ្នាំ ៦០ឆ្នាំ ៦៩ឆ្នាំ (២នាក់) និង៥៩ឆ្នាំ) សរុបចំនួន ១៧នាក់ និងជាបុរស (អាយុ ៦៦ឆ្នាំ ៥៧ឆ្នាំ ៧០ឆ្នាំ (២នាក់) ៦៣ឆ្នាំ (៣នាក់) ៥២ឆ្នាំ ៦៨ឆ្នាំ ៦២ឆ្នាំ ៦១ឆ្នាំ និង៥៨ឆ្នាំ) សរុបចំនួន ១២នាក់។

សម្គាល់៖ អ្នកទេសចរបារាំង២៩នាក់ខាងលើនេះ បូកបន្ថែមអ្នកវិជ្ជមានវីរុសកូវីដ១៩ ជាជនជាតិបារាំង០២នាក់ ដែលបានជូនព័ត៌មានពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២០រួចហើយនោះ គឺសរុបអ្នកវិជ្ជមានវីរុសកូវីដ១៩ មានចំនួន ៣១ នាក់ ក្នុងចំណោមអ្នកទេសចរបារាំងទាំងអស់ ៣៦នាក់ (ក្នុងនេះមាន ០៥នាក់មានតេស្តអវិជ្ជមានវីរុសកូវីដ១៩)។ ពួកគាត់ គឺជាភ្ញៀវទេសចរណ៍ មកដល់ខេត្តព្រះសីហនុនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ហើយគ្រោងវិលត្រឡប់ទៅវិញនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២០។

**២. នៅខេត្តព្រះសីហនុ៖ ០២ ករណី ជាជនជាតិខ្មែរ**

បុរសជនជាតិខ្មែរ អាយុ ៣៩ឆ្នាំ និងអាយុ ៣៣ឆ្នាំ ជាអ្នកមគ្គុទេសក៍ទេសចរឲ្យក្រុមទេសចរបារាំងខាងលើនេះ។

បុគ្គលជនជាតិបារាំង ២៩នាក់ ខាងលើ ស្នាក់នៅសណ្ឋាគារមួយក្នុងក្រុងព្រះសីហនុ ហើយមានជនជាតិខ្មែរ០២នាក់ខាងលើនេះ ជាអ្នកមគ្គុទេសក៍ទេសចរឲ្យក្រុមទេសចរជនជាតិបារាំងទាំងអស់នេះ។

បច្ចុប្បន្ននេះ អ្នកវិជ្ជមានវីរុស ៣១ នាក់ ខាងលើនេះ (ទាំងជនជាតិបារាំង និងខ្មែរ) ត្រូវបានដាក់



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ឲ្យនៅព្យាបាលដាច់ដោយឡែកតាមបន្ទប់នៅក្នុងសណ្ឋាគារមួយ ដោយមានការបិទជាបណ្ដោះអាសន្ន មិនឲ្យមានការចេញចូលដោយគ្មានភារកិច្ចឡើយ។

**៣. សរុបករណីវិជ្ជមានវីរុសកូវីដ១៩ នៅទូទាំងប្រទេស៖**

គ្រឹមម៉ោង២០:០០ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២០ ករណីវិជ្ជមានវីរុសកូវីដ១៩ សរុបទាំងអស់មានចំនួន ៨៤នាក់ (ស្រី ២២នាក់ ប្រុស ៦៣នាក់) ដែលក្នុងនោះ មានជនជាតិ ចិន ០១នាក់ (នៅខេត្តព្រះសីហនុ បានជាសះស្បើយ) អង់គ្លេស ០៣នាក់ (ក្នុងនេះ មាន ០១នាក់ បានជាសះស្បើយហើយ) កាណាដា ០១នាក់ បែលហ្ស៊ិក ០១នាក់ បារាំង ៣៣នាក់ (ក្នុងនេះមានកូនប្រុសបង្កើតអាយុ០៤ខែ) ម៉ាឡេស៊ី ១២នាក់ និងខ្មែរ ៣៣នាក់។

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវឌ្ឍនៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអាទិត្យ ១៤រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**

រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្ដេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩